# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


លេខ៦៦៣៩...សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែសីហា ឆ្នាំ ២០១៥

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**កម្មវត្ថុ÷** ករណីសំណើសុំពិនិត្យនិងសម្រេចស្តីពីការអនុវត្តនីតិវិធីហិរញ្ញវត្ថុសម្រាប់ការចំណាយថវិការបស់អគារធនធាន មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹត្យការ ការចំណាយចុះបេសកកម្មទៅតាមគោលដៅសាលារៀន និងសាកលវិទ្យាល័យតាមបណ្តាខេត្ត។

**យោង÷** លិខិតលេខ២៦៧៦ អយក.ហវ ចុះថ្ងៃទី៣០-០៦-២០១៥ របស់ក្រសួងអប់រំ យុវជននិងកីឡា

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ដោយមានតម្រូវការចាំបាច់ក្នុងការកែសម្រួលនីតិវិធីមួយចំនួន ក្នុងគោលដៅពន្លឿននីតិវិធីចំណាយដើម្បីគាំទ្រដល់ការលើកកម្ពស់សមត្ថភាព និងគុណវុឌ្ឍិគ្រូបង្រៀនក្នុងវិស័យអប់រំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យ និងសម្រេចដូចតទៅ÷

១- ឯកភាពបញ្ចូលនីតិវិធីអនុវត្តចំណាយតាមអគារធនធានក្នុងវិសាលភាពប្រកាសអន្តរក្រសួងលេខ ៣៦៦ សហវ.ប្រក ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការអនុវត្តថវិកាសម្រាប់ដំណើរការសាលារៀនសាធារណៈ។ ចំណែកមជ្ឈមណ្ឌលគរុកោសល្យ និង សាលាគរុកោសល្យនិងវិក្រឹត្យការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសិក្សាបន្ថែមទៀត និងសម្រេចនៅពេលក្រោយ។

២- ចំពោះការកំណត់ប្រាក់បេសកកម្មសម្រាប់មន្ត្រីអនុប្រធានការិយាល័យនៅថ្នាក់មន្ទីរជំនាញរាជធានីខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងចេញសារាចរណែនាំបន្ថែមសម្រាប់អនុវត្តនៅតាមគ្រប់ក្រសួង ស្ថាប័នក្នុងពេលឆាប់ៗនេះ។

៣- ឯកភាពផ្តល់ប្រាក់ហូបចុកនិងប្រាក់ហោប៉ៅ ដើម្បីសម្រួលដល់ការធ្វើដំណើររបស់មន្ត្រីក្នុងការបំពេញបេសកកម្មទៅតាមគោលដៅសាលារៀនដែលមានទីតាំងនៅតំបន់ឆ្ងាយៗ តែស្ថិតក្នុងរង្វង់ក្រុង ស្រុករបស់ខ្លួន តាមអត្រាដូចមានចែងក្នុងមាត្រា៧ នៃអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងអនុវត្តនីតិវិធីចំណាយតាមគោលការណ៍ដូចមានចែងក្នុងប្រកាសលេខ ១៥៨៩ សហវ.ប្រក ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្នើក្រសួងអប់រំ យុវជននិងកីឡារៀបចំសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០២ ស្តីពីការកំណត់ការចំណាយដោយឡែកសម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាពនៅក្រសួងអប់រំ យុវជននិងកីឡា រួចស្នើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេចដោយសារថាអនុក្រឹត្យនេះត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០០២ ជាហេតុធ្វើឱ្យលក្ខខណ្ឌមួយចំនួនអាចមិនឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងក្នុងពេលបច្ចុប្បន្នបាន ។

៥- ចំពោះសំណើសុំអនុវត្តចំណាយថវិការបស់សាកលវិទ្យាល័យដែលមានទីតាំងនៅតាមបណ្តាខេត្តឱ្យនៅត្រឹមមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនមានការយល់ទាស់ទេ ប៉ុន្តែស្នើឱ្យមានការសិក្សា និងពិភាក្សាបន្ថែមទៀតលើនីតិវិធីសម្រាប់អនុវត្ត ដើម្បីឱ្យមានភាពរលូននិងមានប្រសិទ្ធភាព និងដើម្បីធានាអនុលោមភាពតាមគោលការណ៍និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងចាត់ចែងតាមការគួរ។

សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន÷</u>

-អគ្គនាយកដ្ឋានរតនាគារជាតិ

-ឯកសារ-កាលប្បវត្តិ